# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់
## កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ
«ក.ប.ប.»

# ឯកសារសាវតារអំពី
# គោលនយោបាយ និងច្បាប់ស្តីពីការប្រកួតប្រជែង
# ក្នុងបរិបទទូទៅ សម្រាប់ប្រទេសកម្ពុជា



*គាំទ្រដោយ៖*

german cooperation
DEUTSCHE ZUSAMMENARBEIT

Implemented by:

giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

ឯកសារនេះ ដោយមានកិច្ចសហប្រតិបត្តិការពីអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ «**ក.ប.ប.**» ត្រូវបានរៀបចំឡើងក្រោមការគាំទ្រនៃគម្រោង “**ជំរុញភាពប្រកួតប្រជែងនៅក្នុងបរិបទនៃគំនិតផ្តួចផ្តើមសម្រាប់សមាហរណកម្មអាស៊ាន** (COMPETE)” ដែលអនុវត្តដោយទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង (GIZ) និងផ្តល់ការឧបត្ថម្ភដោយក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍន៍។

# ឯកសារសាវតារអំពី គោលនយោបាយ និងច្បាប់ស្តីពីការប្រកួតប្រជែង ក្នុងបរិបទទូទៅ សម្រាប់ប្រទេសកម្ពុជា

## I. សេចក្តីផ្តើម

- ប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកដែលមានចំនួនជាង ១៣០ រួមទាំងរដ្ឋសមាជិកអាស៊ាន ០៩ ក្នុងចំណោម ១០ បានអនុម័តច្បាប់ស្តីពីការប្រកួតប្រជែង។
- ប្រទេសកម្ពុជា បាននឹងកំពុងធ្វើការលើសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង មានរយៈពេលជិត២០ឆ្នាំមកហើយ ដោយមានជំនួយពីជំនាញការអន្តរជាតិមួយចំនួន និងមានឯកសារជាច្រើនទៀតដែលត្រូវបានរៀបចំ។ គួរកត់សម្គាល់ផងដែរថា ច្បាប់ស្តីពីការប្រកួតប្រជែង គឺជាបទប្បញ្ញត្តិមានលក្ខណៈសេដ្ឋកិច្ចនិងមានភាពស្មុគស្មាញ ហើយមានវិសាលភាពគ្រប ដណ្តប់លើសេដ្ឋកិច្ចជាតិនិងមានភាពខុសគ្នាឆ្ងាយពីបទប្បញ្ញត្តិដទៃផ្សេងទៀត។ ដោយសារតែភាពស្មុគស្មាញ និងវិធីសាស្រ្តផ្សេងៗគ្នារបស់ទីប្រឹក្សាអន្តរជាតិ ដែលមកពីប្រទេសដែលមានយុត្តាធិការផ្សេងៗគ្នា ប្រទេសកម្ពុជាបានរៀបចំកែសម្រួលលើសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែងរបស់ខ្លួនស្ទើរតែទាំងអស់ឡើងវិញ នៅពេលមានការផ្លាស់ប្តូរជំនាញការអន្តរជាតិនីមួយៗ ដែលបានជួយគាំទ្រដល់ការតាក់តែងសេចក្តីពាងច្បាប់នេះ។
- ក្នុងរយៈពេលចុងក្រោយនេះ ប្រទេសកម្ពុជាបានយកចិត្តទុកដាក់ទៅលើច្បាប់ដែលស្ថិតក្រោមក្របខ័ណ្ឌពាណិជ្ជកម្មមួយចំនួនមានដូចជា៖ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម ហើយច្បាប់ស្តីពីការប្រកួតប្រជែង ក៏ជាធាតុផ្សំមួយដ៏សំខាន់នៃក្របខ័ណ្ឌច្បាប់នេះផងដែរ។
- សេចក្តីសង្ខេបនេះ គឺបានពន្យល់ពីមូលហេតុដែលច្បាប់ស្តីពីការប្រកួតប្រជែងមានសារៈសំខាន់ទៅលើសេដ្ឋកិច្ចទីផ្សារ និងសម្រាប់ការចូលរួមក្នុងពាណិជ្ជកម្មពិភពលោក និងការវិនិយោគពិភពលោក។ បន្ថែមលើនេះ សេចក្តីសង្ខេបនេះ បានធ្វើការប្រៀបធៀបគ្នា រវាងសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែងដែលបានដាក់ស្នើនេះ ទៅនឹងការអនុវត្តល្អរបស់អន្តរជាតិ ក៏ដូចជាកំណត់នូវបញ្ហាប្រឈមនានាសម្រាប់ការអនុវត្តនៃច្បាប់នេះផងដែរ។
- សេចក្តីលម្អិតបន្ថែមទៀតនៃបទប្បញ្ញត្តិនៃ ច្បាប់ស្តីពីការប្រកួតប្រជែង ដែលបានដាក់ស្នើនេះនឹងត្រូវផ្តល់ជូននៅក្នុងសេចក្តីពន្យល់ច្បាប់។

## II. ហេតុអ្វីបានជាច្បាប់ស្តីពីការប្រកួតប្រជែងមានសារៈសំខាន់

### ចំណុចសំខាន់

- គោលនយោបាយនិងច្បាប់ស្តីពីការប្រកួតប្រជែង គឺបង្កើតក្របខ័ណ្ឌនិងកំណត់នូវទីលានប្រកួតប្រជែងមួយ សម្រាប់ការចូលរួមក្នុងសេដ្ឋកិច្ចទីផ្សារ។
- ច្បាប់ស្តីពីការប្រកួតប្រជែង ដែលជាធាតុដ៏សំខាន់មួយនៃគោលនយោបាយប្រកួតប្រជែង គឺបានធ្វើការហាមឃាត់សកម្មភាពដែលរារាំង រឹតត្បិត ឬបង្ខូចទៅដល់ទីផ្សារណាមួយ ហើយជាទូទៅគឺរៀបចំឱ្យមានការបង្កើតបញ្ញត្តិករសម្រាប់អនុវត្តច្បាប់ស្តីពីការប្រកួតប្រជែង និងលើកកម្ពស់គោលនយោបាយប្រកួតប្រជែង។
- ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែង គឺផ្តល់នូវអត្ថប្រយោជន៍ជាច្រើន ហើយផ្ទុយមកវិញការចំណាយជាច្រើនផ្សេងទៀតនឹងកើតឡើង ប្រសិនជាមិនមានការអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែងនេះ។
- ការបង្កើតច្បាប់ស្តីពីការប្រកួតប្រជែង គឺជាផ្នែកមួយដ៏សំខាន់នៃកាតព្វកិច្ចនិងលក្ខខណ្ឌតម្រូវរបស់ប្រទេសកម្ពុជាក្នុងការចូលរួមប្រកបដោយប្រសិទ្ធភាពនៅក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក។

**មតិយោបល់**

**ក. សេដ្ឋកិច្ចទីផ្សារ**

*"ការប្រកួតប្រជែង ជានិច្ចកាលនឹងដាក់សំពាធឱ្យអាជីវកម្មប្រឹងប្រែងក្នុងការផ្តល់ជម្រើសជាច្រើននៃទំនិញនិងសេវា ដែលមានតម្លៃសមរម្យ ពីព្រោះប្រសិនបើពួកគេមិនធ្វើដូច្នោះទេ អ្នកប្រើប្រាស់នឹងមានជម្រើសច្រើនក្នុងការទៅទិញកន្លែងផ្សេងទៀត។ នៅក្នុងទីផ្សារសេរី ការប្រកបអាជីវកម្ម គួរតែជាហ្គេមនៃការប្រកួតប្រជែង ហើយអ្នកប្រើប្រាស់គឺជាអ្នកទទួលផលចំណេញ"* ដកស្រង់ចេញពីគណៈកម្មាធិការប្រកួតប្រជែងអឺរ៉ុប។

- មាត្រា៥៦ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា "ព្រះរាជាណាចក្រកម្ពុជា អនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។ ការរៀបចំនិងការប្រព្រឹត្តទៅនៃប្រព័ន្ធសេដ្ឋកិច្ចនេះនឹងមានកំណត់ក្នុងច្បាប់"។
    - សេដ្ឋកិច្ចទីផ្សារ គឺមាននិយមន័យជាច្រើនទៀត ប៉ុន្តែគោលការណ៍ដែលត្រូវបានទទួលស្គាល់ជាទូទៅ គឺទីផ្សារដែលដំណើរការដោយផ្អែកលើការប្រកួតប្រជែងក្នុងចំណោមធុរកិច្ច និងអ្នកប្រើប្រាស់។
    - ការប្រកួតប្រជែង គឺជាកត្តាជំរុញនៅពីក្រោយសេដ្ឋកិច្ចទីផ្សារ ព្រោះកត្តានេះបានជំរុញឱ្យក្រុមហ៊ុននានាបង្កើនប្រសិទ្ធភាពកាន់តែច្រើន បង្កើនការវិនិយោគនិងការច្នៃប្រឌិត ហើយនាំឱ្យមានជម្រើសកាន់តែច្រើន រួមទាំងតម្លៃទាបនិងគុណភាពខ្ពស់។
    - សរុបមក នៅពេលមានការប្រកួតប្រជែងកើនឡើង គឺនាំឱ្យមានផលិតភាពកាន់តែច្រើន និងការបែងចែកធនធានប្រកបដោយប្រសិទ្ធភាព។
    - គោលនយោបាយនិងច្បាប់ស្តីពីការប្រកួតប្រជែង គឺជាផ្នែកដ៏សំខាន់មួយនៃការខិតខំរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រនិងបង្កើតឱកាសការងារឱ្យកាន់តែច្រើននៅកម្ពុជា។
        - តម្លៃទាប គឺកើតចេញពីការកើនឡើងនៃការប្រកួតប្រជែង ដែលនាំឱ្យមានអត្ថប្រយោជន៍ជាច្រើនដល់អ្នកប្រើប្រាស់ដែលមានប្រាក់ចំណូលទាប។
        - កំណើនសេដ្ឋកិច្ច គឺកើតចញពីកិច្ចគាំទ្រក្នុងការអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែងបានល្អ ដែលអាចនាំឱ្យមានការកើនឡើងនៃការច្នៃប្រឌិត កំណើននៃការប្រកួតប្រជែងនៅក្នុងការនាំចេញ និងកំណើនផលិតផលក្នុងស្រុកសរុបលឿន។ នេះក៏អាចផ្សារភ្ជាប់ទៅនឹងកំណើនការងារ និងឱកាសកាន់តែច្រើនក៏ដូចជាការកើនឡើង នៃធនធានសម្រាប់ ទ្រទង់ដល់សង្គម និងគោលនយោបាយជាតិផ្សេងៗទៀត។
        - នៅអាហ្វ្រិកខាងត្បូង (South Africa) ធនាគារពិភពលោកបានប៉ាន់ប្រមាណថា ភាពក្រីក្រនឹងថយចុះ ០.៤ ភាគរយ ដោយសារការលុបបំបាត់បទល្មើសកាតែល (Cartel Agreement) ទៅលើប្រភេទទំនិញចំនួន០៤ មុខតែប៉ុណ្ណោះ ទាំងនោះគឺៈ ស្រូវសាលី ពោត បសុបក្សី និងផលិតផលឱសថ[1]។

[1] Cited on https://blogs.worldbank.org/psd/competition-and-poverty-how-far-have-we-come-understanding-connections (last viewed 21 February 2020)

*កំណែទម្រង់នៃការប្រកួតប្រជែងផ្សារភ្ជាប់ទៅនឹងសូចនាករសុខុមាលភាព*




- ការផ្សព្វផ្សាយ ការលើកកម្ពស់ និងការការពារនៃដំណើរប្រព្រឹត្តទៅនៃការប្រកួតប្រជែង គឺជាមុខងារសំខាន់មួយនៃគោលនយោបាយប្រកួតប្រជែង
    - គោលនយោបាយ និងច្បាប់ស្តីពីការប្រកួតប្រជែង គឺមានសារៈសំខាន់ណាស់ក្នុងការកំណត់ និងកែតម្រូវបញ្ហានានានៅក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិ និងដំណើរការទីផ្សារដែលអាចប៉ះពាល់ដល់ដំណើរការប្រកួតប្រជែងនៅក្នុងទីផ្សារ។
    - ច្បាប់ស្តីពីការប្រកួតប្រជែង នឹងកំណត់អំពីការរំលោភបំពានដោយប្រើដំហរឧត្តមភាពលើទីផ្សារនិងសកម្មភាពរបស់អ្នកចូលរួមនៅក្នុងទីផ្សារណាមួយ ដែលអាចរាំងដល់ដំណើរការសមស្របនៃទីផ្សារប្រកួតប្រជែង។ ច្បាប់ស្តីពីការប្រកួតប្រជែង ក៏បានបង្កើតរបបនៃការអនុវត្តមួយដើម្បីការពារ ក៏ដូចជាការកែតម្រូវទៅលើការរំលោភបំពាន និងសកម្មភាពដែលរាំងដល់ការប្រកួតប្រជែងផងដែរ។

## ខ. គោលនយោបាយប្រកួតប្រជែង

**មាត្រា ២.១.១** *"គោលនយោបាយប្រកួតប្រជែងត្រូវបានកំណត់ន័យយ៉ាងទូលំទូលាយថាជាគោលនយោបាយរបស់រដ្ឋាភិបាល ដើម្បីលើកកម្ពស់ ឬគាំទ្រ/រក្សាកម្រិតនៃការប្រកួតប្រជែងនៅក្នុងទីផ្សារនានា និងរួមបញ្ចូលទាំងវិធានការណ៍នានារបស់រដ្ឋាភិបាល ដែលប៉ះពាល់ដោយផ្ទាល់ទៅលើសកម្មភាពរបស់ក្រុមហ៊ុននិងរចនាសម្ព័ន្ធ របស់ឧស្សាហកម្មនិងទីផ្សារ។"*

**មាត្រា ២.១.១.១** *"ចំណុចទីមួយដែលទាក់ទងនឹងការដាក់ចេញនូវគោលនយោបាយនោះគឺ ការជំរុញឱ្យមានការប្រកួតប្រជែងនៅក្នុងទីផ្សារទាំងក្នុងស្រុកនិងថ្នាក់ជាតិ ដូចជាការដាក់ចេញនូវការណែនាំអំពីគោលនយោបាយលើកកម្ពស់ពាណិជ្ជកម្ម ការលុបបំបាត់ចោលការនូវការអនុវត្តពាណិជ្ជកម្មណាដែល*

*មានការរឹតត្បិតដល់ការប្រកួតប្រជែង ការលើកទឹកចិត្តសម្រាប់ការចូលនិងចេញពីទីផ្សារ ការកាត់បន្ថយការអន្តរាគមន៍របស់រដ្ឋាភិបាលដែលមិនចាំបាច់ និងការធ្វើឱ្យមានទំនុកចិត្តទៅលើអំណាចទីផ្សារ។"*

**មាត្រា ២.១.១.២** *"ចំណុចទីពីរ គឺច្បាប់ស្តីពីការប្រកួតប្រជែង ដែលរួមមានទាំងសេចក្តីសម្រេចរបស់តុលាការ និងបទប្បញ្ញត្តិនានា ដែលមានគោលបំណងច្បាស់លាស់ក្នុងការការពារលើការអនុវត្តសកម្មភាពពាណិជ្ជកម្មដែលរាំងដល់ការប្រកួតប្រជែង ការរំលោភបំពានដោយប្រើជំហរឧត្តមភាពលើទីផ្សារ និងការរួមបញ្ចូលគ្នានៃធុរកិច្ចណាមួយដែលរឹតត្បិតដល់ការប្រកួតប្រជែង។ ជាទូទៅគឺផ្តោតទៅលើការគ្រប់គ្រងលើការអនុវត្តសកម្មភាពពាណិជ្ជកម្មដែលរាំងដល់ការប្រកួតប្រជែង (ដូចជាការព្រមព្រៀងដែលរាំង រឹតត្បិត ឬ បង្ខូចការប្រកួតប្រជែង និង ការរំលោភបំពានដោយប្រើជំហរឧត្តមភាពលើទីផ្សារ) និង ការរួមបញ្ចូលគ្នានៃធុរកិច្ចណាមួយដែលរឹតត្បិតដល់ការប្រកួតប្រជែងផងដែរ។"*

*ដកស្រង់ចេញពីគោលការណ៍ណែនាំក្នុងតំបន់អាស៊ានស្តីពីគោលនយោបាយប្រកួតប្រជែង*

- គោលនយោបាយប្រកួតប្រជែង គឺជាក្របខ័ណ្ឌដ៏ធំមួយ ដែលរាជរដ្ឋាភិបាលកម្ពុជានឹងបង្កើត ពង្រឹង និងគ្រប់គ្រងសេដ្ឋកិច្ចទីផ្សារកម្ពុជា។
- គោលនយោបាយប្រកួតប្រជែង គឺជាផ្នែកមួយនៃគោលនយោបាយសេដ្ឋកិច្ចជាតិដែលនឹងបង្កើត និងពង្រឹងមូលដ្ឋានទីផ្សារ ព្រមទាំងធានាដល់ប្រសិទ្ធភាពនៃសេដ្ឋកិច្ចកម្ពុជា។
- គោលនយោបាយប្រកួតប្រជែង គឺរួមបញ្ចូលនូវវិធានការនានារបស់រដ្ឋាភិបាល ដែលមានផលប៉ះពាល់ដល់ការប្រកួតប្រជែង រួមមានបរិយាកាសនៃបទប្បញ្ញត្តិសម្រាប់អាជីវកម្ម គោលនយោបាយឧស្សាហកម្មនិងពាណិជ្ជកម្ម ការវិនិយោគពីបរទេស បទប្បញ្ញត្តិតាមវិស័យនានា របាំងពាណិជ្ជកម្មមិនមែនពន្ធគយ និងការលើកកម្ពស់/ការការពារទីផ្សារក្នុងស្រុក ឬ អ្នកចូលរួមក្នុងទីផ្សារ។
- ការអនុវត្តគោលនយោបាយប្រកួតប្រជែង គឺបង្ហាញពីការយកចិត្តទុកដាក់របស់កម្ពុជា លើសេដ្ឋកិច្ចទីផ្សារប្រកបដោយប្រសិទ្ធភាព ហើយមួយវិញទៀតនោះ គឺយើងអាចប្រើប្រាស់សម្រាប់ការពារការប្រកួតប្រជែង និងការរួមចំណែកក្នុងការការពារផលប្រយោជន៍ជាតិជាក់លាក់ណាមួយដូចជាសហគ្រាសធុនតូចនិងមធ្យម។ សហគ្រាសធុនតូចនិងមធ្យមទាំងនេះ គឺបង្កើតបានជាចំណែកដ៏ធំមួយនៃវិស័យឯកជន ដែលជាញឹកញាប់ត្រូវប្រឈមនឹងបញ្ហាប្រកួតប្រជែងធំៗ និងជំរុញឱ្យមានការរីកចម្រើនរបស់ខ្លួនឱ្យកាន់តែខ្លាំង នៅពេលប្រកួតប្រជែងជាមួយ គូប្រកួតប្រជែងធំៗទាំងក្នុងស្រុកនិងក្រៅស្រុក ដែលពួកគេអាចស្ថិតក្នុងជំហរមួយអាចបំពានអំណាចទីផ្សារ ឬបានចូលរួមក្នុងការប្រព្រឹត្តសកម្មភាពដែលរារាំងដល់ការប្រកួតប្រជែង។
- ច្បាប់ស្តីការប្រកួតប្រជែង គឺជាធាតុមួយដ៏សំខាន់របស់គោលនយោបាយប្រកួតប្រជែងដែលមានតួនាទី៖
  - បង្កើតក្របខ័ណ្ឌសម្រាប់បញ្ញត្តិករក្នុងការជំរុញ និងផ្សព្វផ្សាយគោលនយោបាយប្រកួតប្រជែង និងពង្រឹងការអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែង។
  - បង្កើតវិធាននិងក្រមសីលធម៌ ដើម្បីបង្កើតនូវទីលានប្រកួតប្រជែងស្មើភាពមួយទាំងក្នុងស្រុក និងអន្តរជាតិសម្រាប់អាជីវកម្មខ្នាតតូច ខ្នាតមធ្យម និងខ្នាតធំ ដើម្បីធ្វើការប្រកួតប្រជែងដោយសមភាពនៅក្នុងសេដ្ឋកិច្ចទីផ្សារកម្ពុជា។
- សារៈសំខាន់នៃច្បាប់ស្តីពីការប្រកួតប្រជែង ត្រូវបានគេសង្កេតឃើញនៅក្នុងសកម្មភាពនៃប្រទេសជិតខាងរបស់កម្ពុជា មានជាអាទិ៍ ថៃនិងវៀតណាម ដែលនាពេលថ្មីៗប្រទេសទាំងពីរនេះ បានធ្វើវិសោធនកម្មយ៉ាងច្រើនទៅលើច្បាប់ស្តីពីការប្រកួតប្រជែងរបស់ខ្លួន ដើម្បីពង្រីកវិសាលភាពនិងប្រសិទ្ធភាពរបស់ពួកគេ។
  - ចំណែកឯបណ្តារដ្ឋសមាជិកអាស៊ានផ្សេងទៀត រួមមាន៖ ម៉ាឡេស៊ី និងឥណ្ឌូនេស៊ី ក៏បាននិងកំពុងពិនិត្យឡើងវិញលើការធ្វើវិសោធនកម្មច្បាប់របស់ខ្លួនផងដែរ។

- ជាតុសំខាន់មួយទៀតនៃក្របខ័ណ្ឌច្បាប់នេះ គឺកិច្ចការពារអ្នកប្រើប្រាស់។ ជាទូទៅ ច្បាប់នេះមានចែងពីបទប្បញ្ញត្តិស្តីពីការការពារអ្នកប្រើប្រាស់ ឬការធ្វើធុរកិច្ចមិនស្មោះត្រង់ ដើម្បីឆ្លើយតបទៅនឹងការបង្ខូចដល់ទីផ្សារដែលមិនផ្អែកលើសេដ្ឋកិច្ច។
  - ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និងច្បាប់ស្តីពីការប្រកួតប្រជែង ត្រូវបានគេមើលឃើញថាជាច្បាប់ដែលបំពេញគ្នាទៅវិញទៅមក និងត្រូវដាក់ឱ្យអនុវត្តទន្ទឹមគ្នាដើម្បីលើកកម្ពស់សុខុមាលភាពអ្នកប្រើប្រាស់។
  - ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និងច្បាប់ស្តីពីការប្រកួតប្រជែង នៅក្នុងប្រទេសមួយចំនួនរួមទាំងបណ្តារដ្ឋសមាជិកអាស៊ានផ្សេងទៀត គឺត្រូវបានដាក់ឱ្យអនុវត្តដោយបញ្ញត្តិករតែមួយ។

*"គោលបំណងចុងក្រោយនៃគោលនយោបាយប្រកួតប្រជែង និងគោលនយោបាយកិច្ចការពារអ្នកប្រើប្រាស់គឺលើកកម្ពស់សុខុមាលភាពដល់អ្នកប្រើប្រាស់។ គោលនយោបាយទាំងពីរនេះ គឺត្រូវបានកំណត់ទិសដៅ ក្នុងការធានាថា ទីផ្សារមានដំណើរការប្រកបដោយប្រសិទ្ធភាព និងអាចកែតម្រូវនូវការខូចខាតទីផ្សារ ដោយគ្រាន់តែប្រើប្រាស់មធ្យោបាយផ្សេងៗគ្នា ក្នុងការសម្រេចឱ្យបាននូវទិសដៅនេះ។"*

*ប្រភព: លេខាធិការដ្ឋាន UNCTAD ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤*

## គោលនយោបាយនិងច្បាប់ស្តីពីការប្រកួតប្រជែង




## គ. ការចំណាយ និងអត្ថប្រយោជន៍នៃរបបប្រកួតប្រជែង

*"គោលនយោបាយនិងច្បាប់ស្តីពីការប្រកួតប្រជែង គឺជាឧបករណ៍ដ៏សំខាន់មួយ ដើម្បីលើកកម្ពស់ការប្រកួតប្រជែងដោយស្មើភាព និងធ្វើឱ្យទីផ្សារដំណើរការកាន់តែមានប្រសិទ្ធភាព។ ការអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែងប្រកបដោយប្រសិទ្ធភាព គឺអាចចូលរួមចំណែកយ៉ាងច្រើនដល់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ រួមទាំងសុខុមាលភាពរបស់អ្នកប្រើប្រាស់ផងដែរ។"*

*ដកស្រង់ចេញពី សៀវភៅណែនាំស្តីពីគោលនយោបាយនិងច្បាប់ស្តីពីការប្រកួតប្រជែងនៅក្នុងអាស៊ានសម្រាប់ធុរកិច្ច ឆ្នាំ២០១៧, ទំព័រទី ៥*

- ច្បាប់ស្តីពីការប្រកួតប្រជែង គឺបានហាមឃាត់ឬកំណត់នូវ "សសរស្តម្ភទាំងបី" ដែលមានដូចជា ការព្រមព្រៀងដែលរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង ការរំលោភបំពានដោយប្រើជំហរឧត្តមភាពលើទីផ្សារ និងការរួមបញ្ចូលគ្នានៃធុរកិច្ចដែលរារាំងដល់ការប្រកួតប្រជែង ហើយជះឥទ្ធិពលនៅក្នុងយុត្តាធិការរបស់ប្រទេសនីមួយៗ។
- ច្បាប់ស្តីការប្រកួតប្រជែង អាចផ្តល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ចជាច្រើនផ្នែក។ ចំណុចសំខាន់ពីរ នៃអត្ថប្រយោជន៍ទាំងនោះរួមមាន ការការពារ និងដោះស្រាយនូវការខូចខាតដល់ការប្រកួតប្រជែងណាមួយជាក់លាក់ ពង្រឹងដំណើរការ និងប្រតិបត្តិការនៃសេដ្ឋកិច្ចទីផ្សារដែលមានការប្រកួតប្រជែង និងធ្វើឱ្យវាកាន់តែមានប្រសិទ្ធភាព។
    - ច្បាប់ស្តីពីការប្រកួតប្រជែង មិនត្រឹមតែបញ្ជាក់ពី "ច្បាប់នៃការប្រកួត" ប៉ុណ្ណោះទេ ប៉ុន្តែការអនុវត្តមួយប្រកបដោយប្រសិទ្ធភាព វាអាចទប់ស្កាត់ដល់សកម្មភាពដែលបំពានដល់ការប្រកួតប្រជែងបានផងដែរ។
- ពាក់ព័ន្ធដល់ការខូចខាតជាក់លាក់ណាមួយ យើងមានការអះអាងសំខាន់ៗជាច្រើនដែលបញ្ជាក់ថាមានការព្រមព្រៀងខ្សែជេក(កាតែល) ដោយមានការចូលរួមជាមួយបុគ្គលពីក្រៅប្រទេស (សមាជិកកាតែល) គឺធ្វើឱ្យមានការឡើងថ្លៃខ្ពស់ច្រើនជាងតម្លៃដែលលក់នៅក្នុងស្រុកនៃប្រទេសដ៏ទៃផ្សេងទៀត។ ក្រៅពីនេះក៏មានការអះអាង និងការទទួលស្គាល់ពីមជ្ឈដ្ឋានទូទៅផ្សេងទៀតនោះ គឺការរំលោភបំពានដោយប្រើជំហរឧត្តមភាពលើទីផ្សារ និងការរួមបញ្ចូលគ្នានៃធុរកិច្ចដែលរារាំងដល់ការប្រកួតប្រជែងក៏បណ្តាលឱ្យមានផលប៉ះពាល់និងការចំណាយផ្សេងៗលើសេដ្ឋកិច្ចផងដែរ។គួរបញ្ជាក់ផងដែរថា បញ្ហាទាំងនេះគឺមានលក្ខណៈខុសៗគ្នាដែលកំណត់ទៅតាមករណីមួយៗ[2]។

<u>**ឧទាហរណ៍៖**</u>

- ផលប៉ះពាល់នោះមានផលវិជ្ជមានទៅលើសុខុមាលភាពដល់អ្នកប្រើប្រាស់ ដែលមានចំនួនប្រមាណ ១៤៨លានដុល្លារសហរដ្ឋអាមេរិក ស្របតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការប្រកួតប្រជែងឥណ្ឌូនេស៊ី (KPPU) លើបទល្មើសកាតែល[3]។
- ការសិក្សាមួយលើការប្រមូលទិន្នន័យដ៏ធំមួយបានកំណត់ថា តម្លៃមធ្យមបន្ថែមដោយការព្រមព្រៀងខ្សែជេក (កាតែល) ក្នុងរយៈពេលដែលបានសិក្សានោះគឺមាន ២៣%[4]។
- របាយការណ៍មួយរបស់អង្គការ OECD បានធ្វើការប៉ាន់ស្មានថាចំណាយសរុបក្នុងកម្រិតសាកលលោកលើការព្រមព្រៀងខ្សែជេក នេះគឺមានចំនួនរាប់ពាន់លានដុល្លារសហរដ្ឋអាមេរិកក្នុងមួយឆ្នាំ[5]។

- បើគិតពីអត្ថប្រយោជន៍នៃសេដ្ឋកិច្ចវិញ មានការសិក្សាជាច្រើនបានព្យាយាមធ្វើការវាយតម្លៃទៅលើផលប្រយោជន៍នៃការអនុម័តច្បាប់ស្តីពីការប្រកួតប្រជែង ឬការអនុវត្តគោលនយោបាយប្រកួតប្រជែង។

<u>**ឧទាហរណ៍៖**</u>

- មានការរកឃើញជាក់ស្តែងជាច្រើន ដែលចេញពីការផ្លាស់ប្តូរនៃគោលនយោបាយគាំទ្រដល់ការប្រកួតប្រជែង ហើយបានអះអាងថាការប្រកួតប្រជែង គឺនាំមកនូវកំណើនផលិតភាព សុខុមាលភាព និង សេដ្ឋកិច្ចរយៈពេលវែង[6]។
- ទិន្នន័យពីប្រទេសចំនួន ១៥៤ ចាប់តាំងពីឆ្នាំ១៩៦០ ដល់ឆ្នាំ២០០៧ បានអះអាងថា ពេលដាក់ចេញនូវច្បាប់ស្តីពីការប្រកួតប្រជែង គឺមានផលវិជ្ជមានយ៉ាងខ្លាំងទៅលើការអភិវឌ្ឍន៍និងកំណើនសេដ្ឋកិច្ច[7]។

- ការអះអាងពីសាស្ត្រាចារ្យ Dovile Venskutonyte & Maarten Pieter Schinkel ពីសាកលវិទ្យាល័យ Amsterdam បានបង្ហាញថា សកម្មភាពរារាំងដល់ការប្រកួតប្រជែង គឺអាចជះផលប៉ះពាល់ខ្លាំងជាពិសេសនៅក្នុងប្រទេសកំពុង

---

[2] Productivity and Competition : A summary of the evidence. Competition and Markets Authority UK. 9 July 2015

[3] See Kompetisia, Newsletter of Indonesia Competition Law and Policy, Vol. 2/2011 – KPPU Decision for the Interests of Consumers

[4] Conner, J.M. (2004), Price-Fixing Overcharges (Revised 3rd Edition)

[5] See OECD (2002), *Fighting Hard Core Cartels: Harm, Effective Sanctions and Leniency Programmes pgs. 72-6*

[6] Competition, Innovation and Productivity Growth: A review of theory and evidence, Sanghoon Ahn, OECD Working Paper 317, 17 Jan, 2002

[7] Antitrust Law and the Promotion of Democracy and Economic Growth Niels Petersen January 2011, pg. 3

អភិវឌ្ឍន៍ ព្រោះថាផលប៉ះពាល់ធំៗនៃសុខុមាលភាព គឺខ្ពស់នៅពេលដែលថ្លៃចំណាយទៅលើសកម្មភាពប្រកួតប្រជែងដែលមិនមានបទប្បញ្ញត្តិត្រឹមត្រូវ ដែលនេះបានដាក់បន្ទុកទៅលើចំនួនប្រជាជនដែលមានប្រាក់ចំណូលទាប សូម្បីតែការយកតម្លៃលើសបន្តិចបន្តួចក៏មានការជះឥទ្ធិពលមិនល្អដល់ការចំណាយរបស់ពួកគាត់ផងដែរ៖។

- សារៈសំខាន់នៃការការពារដែលត្រូវបានផ្តល់ដោយច្បាប់ស្តីពីការប្រកួតប្រជែងប្រកបដោយប្រសិទ្ធភាព ត្រូវបានបង្ហាញនៅក្នុងការរួមបញ្ចូលគ្នានៃធុរកិច្ចរវាងក្រុមហ៊ុន Uber និង Grab។ បណ្តារដ្ឋសមាជិកអាស៊ាន មួយចំនួនដែលមានសកម្មភាពច្រើនទៅលើការរួមបញ្ចូលគ្នានៃធុរកិច្ចនោះ គឺមានប្រទេសសិង្ហបុរី ប្រទេសហ្វីលីពីន និងប្រទេសវៀតណាម ដែលបានចាត់វិធានការទាក់ទងនឹងការរួមបញ្ចូលគ្នានេះ។ ជាក់ស្តែង ប្រទេសម៉ាឡេស៊ីជាប្រទេសដែលមិនមានចែងអំពីបទប្បញ្ញត្តិក្នុងការគ្រប់គ្រង លើការរួមបញ្ចូលគ្នានៃធុរកិច្ចទៅក្នុងច្បាប់ស្តីពីការប្រកួតប្រជែងរបស់ខ្លួន បានសម្រេចដាក់ការបំពានច្បាប់នេះ ឱ្យស្ថិតនៅក្រោមបទប្បញ្ញត្តិពាក់ព័ន្ធដល់ការរំលោភបំពានដោយប្រើដំហរឧត្តមភាពលើទីផ្សារទៅវិញ។ កង្វះខាតនៃឧបករណ៍គតិយុត្តនេះ បានធ្វើឱ្យម៉ាឡេស៊ីផ្សារភ្ជាប់បញ្ហានេះទៅនឹងការពិចារណាលើការដាក់បញ្ចូលបទប្បញ្ញត្តិពាក់ព័ន្ធដល់ការរួមបញ្ចូលគ្នានៃធុរកិច្ចទៅក្នុងច្បាប់ស្តីពីប្រកួតប្រជែងរបស់ខ្លួន។ នៅបណ្តារដ្ឋសមាជិកអាស៊ានមួយចំនួន ស្ថាប័នអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែងអាចចាត់វិធានការផ្សេងៗ ដើម្បីស្តារឡើងវិញនូវផលប៉ះពាល់នៃការធ្វើធុរកិច្ចដែលរារាំងដល់ការប្រកួតប្រជែង ទោះបីជាមិនអាចរារាំងវាពីការកើតមានឡើងក៏ដោយ។ មន្ត្រីនៃស្ថាប័នអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែងនៅក្នុងបណ្តារដ្ឋសមាជិកអាស៊ាន បានធ្វើការបញ្ចេញមតិថា ពួកគេបានសហការ និងពិគ្រោះយោបល់គ្នាទៅវិញទៅមកក្នុងអំឡុងពេលស៊ើបអង្កេតលើករណីរួមបញ្ចូលគ្នានៃធុរកិច្ច និងបានពិភាក្សាអំពីបញ្ហាពាក់ព័ន្ធដូចជា ភស្តុតាង និយមន័យទីផ្សារ ទ្រឹស្តីនៃផលប៉ះពាល់។ល។ កិច្ចសហប្រតិបត្តិការប្រភេទនេះធានាថាបញ្ហាប្រកួតប្រជែងនៅក្នុងអាស៊ាន អាចត្រូវបានដោះស្រាយឱ្យកាន់តែមានប្រសិទ្ធភាពជាមួយដំណោះស្រាយស្របគ្នា។

<u>**ភាពខុសគ្នារវាងការចំណាយ និងអត្ថប្រយោជន៍នៃរបបប្រកួតប្រជែង**</u>

| **ការចំណាយ** | **អត្ថប្រយោជន៍** |
|---|---|
| ការចំណាយផ្ទាល់ របស់បញ្ញត្តិករ (រដ្ឋបាល) | |
| **ការចំណាយផ្ទាល់របស់ក្រុមហ៊ុន** | **អត្ថប្រយោជន៍ផ្ទាល់របស់ក្រុមហ៊ុន** |
| • ការចំណាយលើការប្រតិបត្តិតាមច្បាប់<br>• ការចំណាយលើដំណើរការដាក់លាក់ | • ការកាត់បន្ថយការអនុវត្តនានាដែលរារាំងដល់ការប្រកួតប្រជែងក្នុងទីផ្សារ<br>• ការបង្កើនឱកាសនិងថ្លៃដើមទាប នៅក្នុងទីផ្សារប្រកបដោយប្រសិទ្ធភាព |
| **ផលប៉ះពាល់អវិជ្ជមានសម្រាប់សេដ្ឋកិច្ច** | **ផលប៉ះពាល់វិជ្ជមានសម្រាប់សេដ្ឋកិច្ច** |
| • ភាពគ្មានប្រសិទ្ធភាពនៃការបែងចែក<br>• ភាពគ្មានប្រសិទ្ធភាពនៃផលិតកម្ម<br>• ការបន្ថយនៃការលើកទឹកចិត្ត (ប្រសិទ្ធភាព/ការច្នៃប្រឌិតថយចុះ)<br>• គុណភាពនៃទំនិញ/សេវាថយចុះ<br>• ការរឹតត្បិតលើមុខងារទីផ្សារ | • ប្រសិទ្ធភាពនៃការបែងចែក<br>• ប្រសិទ្ធភាពនៃផលិតកម្ម<br>• ប្រសិទ្ធភាព/ការច្នៃប្រឌិតកើនឡើង<br>• គុណភាពនៃទំនិញនិងសេវាកើនឡើង<br>• មុខងារទីផ្សារកើនឡើង |
| **ការចំណាយដោយមិនផ្ទាល់ផ្នែកបទប្បញ្ញត្តិ** | **អត្ថប្រយោជន៍ដោយមិនផ្ទាល់ផ្នែកបទប្បញ្ញត្តិ** |
| • ភាពមិនប្រាកដនៃបទប្បញ្ញត្តិ<br>• ការចាប់យកនូវបទប្បញ្ញត្តិ | • ភាពប្រាកដនៃបទប្បញ្ញត្តិ<br>• ឥទ្ធិពលនៃការគំរាមកំហែង |

8 Bespoke Competition Policy for Developing Countries Dovile Venskutonyte & Maarten Pieter Schinkel University of Amsterdam June 2015

| | |
|---|---|
| | • ការជំរុញមុខងាររបស់ទីផ្សារសេដ្ឋកិច្ច<br>• ការជំរុញគុណភាពនៃច្បាប់ស្តីពីការប្រកួតប្រជែង<br>• ការបំពេញនូវកាតព្វកិច្ចអន្តរជាតិ<br>• ការបង្កើនបរិយាកាសទាក់ទាញសម្រាប់ពាណិជ្ជកម្ម និងការវិនិយោគអន្តរជាតិ |
| **ការចំណាយផ្នែកសង្គម** | **អត្ថប្រយោជន៍ផ្នែកសង្គម** |
| • ការចំណាយនៃការបែងចែក<br>• ការកាត់បន្ថយគុណភាព/ស្ថេរភាពនៃការផ្គត់ផ្គង់<br>• ផលអវិជ្ជមានដល់អតិថិជនដែលងាយរងគ្រោះ | • អត្ថប្រយោជន៍នៃការបែងចែក<br>• ការជំរុញគុណភាព/ស្ថេរភាពនៃការផ្គត់ផ្គង់<br>• ផលវិជ្ជមានដល់អតិថិជនដែលងាយរងគ្រោះ |

- គោលនយោបាយនិងច្បាប់ស្តីពីការប្រកួតប្រជែងប្រកបដោយប្រសិទ្ធភាព គឺអាចមានការចំណាយច្រើន។ ការចំណាយផ្ទាល់នឹងត្រូវកើតមានក្នុងដំណើរការអនុម័តច្បាប់ស្តីពីការប្រកួតប្រជែង ក៏ដូចជា ក្នុងការត្រួតពិនិត្យច្បាប់ជាប្រចាំ និងការធ្វើវិសោធនកម្មលើបទប្បញ្ញត្តិសំខាន់ៗមួយចំនួននៅក្នុងច្បាប់ស្តីពីការប្រកួតប្រជែង ច្បាប់ពាក់ព័ន្ធ និងបទប្បញ្ញត្តិផ្សេងៗទៀត ដែលចាំបាច់ក្នុងការលើកកម្ពស់គោលនយោបាយប្រកួតប្រជែង។ លើសពីនេះទៀត ការចំណាយដែលគួរឱ្យកត់សម្គាល់នោះ គឺការចំណាយក្នុងការបង្កើតស្ថាប័ន ការបណ្តុះបណ្តាល និងចំណាយប្រតិបត្តិការនានាក្នុងដំណើរការនៃស្ថាប័នប្រកួតប្រជែងរួមមាន ការអភិវឌ្ឍន៍ និងការរក្សាជំនាញ ការសិក្សាទៅលើទីផ្សារនិងបទប្បញ្ញត្តិ ការស៊ើបអង្កេត ការផ្សព្វផ្សាយ និងសកម្មភាពនៃកិច្ចគាំទ្រផ្សេងៗទៀត។ នៅក្នុងវិស័យឯកជន ការចំណាយក៏ជាបន្ទុកលើអាជីវកម្មផងដែរ ដើម្បីធ្វើការអនុវត្តឱ្យស្របទៅតាមច្បាប់ស្តីពីការប្រកួតប្រជែង ដែលទាំងនេះរួមមាន ការជូនដំណឹងនៃការការរួមបញ្ចូលគ្នានៃធុរកិច្ច ការលុបចោលនៅសកម្មភាពដែលរាំងដល់ការប្រកួតប្រជែង និងការអនុវត្តកម្មវិធីអនុលោមភាពផ្សេងៗទៀត។
- ក្រៅពីអត្ថប្រយោជន៍លើសេដ្ឋកិច្ចដូចបានពិភាក្សាខាងលើ ក៏មានការផ្តល់ជាមតិយោបល់លើអត្ថប្រយោជន៍ ក្នុងការអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែងដែលយើងអាចទទួលនូវផលច្រើនជាងការចំណាយដែលបានរៀបរាប់ខាងលើដូចជា៖
  - ស្ថាប័នប្រកួតប្រជែងប្រទេសប៉េរូ បានរកឃើញថាក្នុងរយៈពេល ០៧ឆ្នាំដំបូង នៃប្រតិបត្តិការរបស់ខ្លួន គឺបានផ្តល់នូវផលប្រយោជន៍ដល់សេដ្ឋកិច្ចចំនួន ១២០លានដុល្លារសហរដ្ឋអាមេរិក បើប្រៀបធៀបទៅនឹងការចំណាយទៅលើប្រតិបត្តិការចំនួន ២០លានដុល្លារសហរដ្ឋអាមេរិកនោះ[9]។
  - មួយវិញទៀត សហរដ្ឋអាមេរិក និងប្រទេសហូឡង់ បានលើកឡើងនូវផលប្រយោជន៍ដែលកើតចេញពីការអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែងគឺ ទទួលបានច្រើនជាងការចំណាយ[10]។

### ឃ. ផលចំណេញនៅក្នុងឆាកអន្តរជាតិពីការអនុម័តច្បាប់ស្តីពីការប្រកួតប្រជែងរបស់ប្រទេសកម្ពុជា

### ការប្តេជ្ញាចិត្តនៅក្នុងឆាកអន្តរជាតិ

- ការអនុម័តច្បាប់ស្តីពីការប្រកួតប្រជែង នឹងបំពេញកាតព្វកិច្ចអន្តរជាតិសំខាន់ចំនួន ០២គឺ៖
  - ប្រទេសកម្ពុជាបានធ្វើការប្តេជ្ញាចិត្តបង្កើតច្បាប់ស្តីពីការប្រកួតប្រជែងមួយនៅឆ្នាំ២០០៦ ដែលជាផ្នែកមួយនៃកិច្ចព្រមព្រៀងចរចាឆ្នាំ២០០៤ ទាក់ទងនឹងការចូលរួមជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក[11]។
  - បណ្តារដ្ឋសមាជិកអាស៊ានទាំងអស់ បានប្តេជ្ញាចិត្តក្នុងដាក់ចេញនូវគោលនយោបាយប្រកួតប្រជែង នៅឆ្នាំ ២០១៥ ក្រោមផែនការលម្អិតរបស់សហគមន៍សេដ្ឋកិច្ចអាស៊ាន។ ជាមួយគ្នានេះផងដែរ បណ្តារដ្ឋសមាជិក

---

9 See Caceres, A (2000), “Indecopi’s first seven years” in Beatriz Boza, ed., *The Role of the State in Competition and IP Policy in Latin America: towards an academic audit of Indecopi*, Lima.
10 See Hüschelrath, K. (2008), *The costs and benefits of Antitrust Enforcement*
11 *See* the Report of the Working Party on the Accession of Cambodia (WT/ACC/KHM/21 15 August 2003).

អាស៊ានចំនួន០៩ ក្នុងចំណោម១០ បាននឹងកំពុងអនុម័តច្បាប់ស្តីពីការប្រកួតប្រជែងរបស់ខ្លួន បើគិតត្រឹមចុងឆ្នាំនេះ។

- ខណៈពេលដែលកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន (FTA) បានកំណត់នូវការប្រកួតប្រជែងជាកាតព្វកិច្ចនោះ បទប្បញ្ញត្តិនិងជំពូកជាច្រើននៃគោលនយោបាយប្រកួតប្រជែង បានក្លាយជាផ្នែកមួយក្នុងការកើនឡើងនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីចំនួន ៩០ភាគរយ ដែលបានចុះបញ្ជីជាមួយអង្គការពាណិជ្ជកម្មពិភពលោក។ គួរបញ្ជាក់ផងដែរថា ក្នុងកិច្ចព្រមព្រៀងទាំងនោះមានភ្ជាប់នូវបទប្បញ្ញត្តិទាក់ទងនឹងការប្រកួតប្រជែងផងដែរ (លើសពី៦០ភាគរយ មុនឆ្នាំ១៩៩០)[12]។
    - កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយថ្នាក់តំបន់ (RCEP) ដែលកម្ពុជារំពឹងថានឹងផ្តល់សច្ចាប័នដល់កិច្ចព្រមព្រៀងនេះ តម្រូវឱ្យភាគីមាននិងអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែង និងបទប្បញ្ញត្តិដែលមានចែងនូវសកម្មភាពដែលរារាំងដល់ការប្រកួតប្រជែង និងការជានាឱ្យមានការអនុវត្តដោយឯករាជ្យភាព។

## សេដ្ឋកិច្ចសកល/ការវិនិយោគផ្ទាល់ពីបរទេស

- ច្បាប់ស្តីពីការប្រកួតប្រជែង គឺជាផ្នែកមួយនៃក្របខ័ណ្ឌសេដ្ឋកិច្ចនិងពាណិជ្ជកម្មជាសកល ដែលមានប្រទេសចំនួនជាង ១៣០ បានអនុម័តច្បាប់ស្តីពីការប្រកួតប្រជែងក្នុងរយៈពេល ៣០ឆ្នាំចុងក្រោយនេះ។ ដូចដែលបានកត់សម្គាល់ខាងលើ ច្បាប់នេះ បានរួមចំណែកមួយយ៉ាងសំខាន់នៃកិច្ចព្រមពាណិជ្ជកម្មសេរី។
- ប្រទេសកម្ពុជា នឹងមានភាពទាក់ទាញសម្រាប់ពាណិជ្ជកម្មនិងការវិនិយោគទាំងក្នុងតំបន់ និងអន្តរជាតិដោយមាន សេដ្ឋកិច្ចទីផ្សារត្រឹមត្រូវ ហើយត្រូវបានការពារដោយច្បាប់ស្តីពីការប្រកួតប្រជែង ដើម្បីឱ្យក្រុមហ៊ុនបរទេសកាន់តែមានទំនុកចិត្តថាពួកគេនឹងមិនត្រូវបានបាត់បង់ឱកាសក្នុងការប្រកួតប្រជែង ដោយសារតែការប្រកួតប្រជែងមិនស្មោះត្រង់ពីទីផ្សារក្នុងស្រុកនោះទេ។

  *ដូច្នេះ ការប្រកួតប្រជែង នឹងបង្កើននូវភាពទាក់ទាញនៃប្រទេសមួយ ដែលជាទីតាំងសម្រាប់ធ្វើធុរកិច្ច ក៏ដូចជាបង្កឱ្យមានបរិយាកាសវិនិយោគជាតិនិងអន្តរជាតិ។ ជាមួយគ្នានេះផងដែរ ការប្រកួតប្រជែងក៏បានផ្តល់នូវអត្ថប្រយោជន៍សម្រាប់អ្នកប្រើប្រាស់តាមរយៈការផ្តល់នូវតម្លៃទាប សេវាកម្មមានភាពប្រសើរឡើង និងមានជម្រើសកាន់តែច្រើន។ ក្នុងន័យនេះ ការប្រកួតប្រជែង គឺបង្កើតនូវសុខុមាលភាពដល់អ្នកប្រើប្រាស់គ្រប់ៗគ្នា។*

- ច្បាប់ស្តីពីការប្រកួតប្រជែង អាចទប់ស្កាត់សកម្មភាពដែលរារាំងដល់ការប្រកួតប្រជែងទាំងក្នុងកម្រិតជាតិ និងអន្តរជាតិ។ តាមការសិក្សារបស់ធនាគារពិភពលោក (WB) បានបង្ហាញថា នៅឆ្នាំ១៩៩៧ ប្រទេសកំពុងអភិវឌ្ឍន៍ បាននាំចូលនូវទំនិញចំនួន ៨១.១ពាន់លានដុល្លារសហរដ្ឋអាមេរិក លើវិស័យឧស្សាហកម្ម ដែលបទល្មើសកាតែលអន្តរជាតិ (ការឃុបឃិតគ្នាក្នុងការកំណត់តម្លៃ) ត្រូវបានរកឃើញនៅក្នុងវិស័យឧស្សាហកម្មទាំងនោះ ក្នុងអំឡុងទសវត្សឆ្នាំ៩០។ ការនាំចូលក្នុងវិស័យឧស្សាហកម្មនោះស្មើនឹង ៦.៧% នៃការនាំចូលសរុប និងស្មើនឹង ១.២% នៃផលិតផលក្នុងស្រុកសរុបរបស់ប្រទេសកំពុងអភិវឌ្ឍន៍[13]។
- ខ្សែសង្វាក់ផ្គត់ផ្គង់ដែលមានលក្ខណៈជាសកល ដូចដែលបានកើតឡើងជាក់ស្តែងដោយបញ្ហាផលិតកម្មដែលបណ្តាលមកពីជំងឺកូវីដ-១៩ (Covid-19) នៅក្នុងប្រទេសចិន ហើយវាជាសារៈសំខាន់មួយសម្រាប់ប្រទេសកម្ពុជា ក្នុងការធានាច្បាប់ស្តីពីការប្រកួតប្រជែងរបស់ខ្លួនដែលត្រូវបានអនុម័ត និងធ្វើការអនុវត្តប្រកបដោយប្រសិទ្ធភាព ដើម្បីការពារ និងលើកកម្ពស់នូវគោលជំហររបស់ខ្លួនទាំងនៅក្នុងពាណិជ្ជកម្មពិភពលោកនិងក្នុងតំបន់។

---

12 Competition Policy within the context of Free Trade Agreements, François-Charles Laprévote, 5 December 2019

13 Levenstein, Margaret and Valerie Suslow, *Private International Cartels and Their Effect on Developing Countries* (Background Paper for the World Bank's World Development Report 2001, 9 January 2001)

*អ្វីដែលកាន់តែច្បាស់ទៀតនោះគឺ សកម្មភាពដែលរារាំងដល់ការប្រកួតប្រជែងទាំងក្នុងនិងក្រៅប្រទេស បានធ្វើឱ្យប៉ះពាល់ដល់ដំណើរការនៃការពង្រីកពាណិជ្ជកម្មរបស់ប្រទេសកំពុងអភិវឌ្ឍន៍កាន់តែខ្លាំងជាងអ្វីដែលបានគិតពីមុន។*

*លេខាធិការដ្ឋាន UNCTAD-ទំព័រទី៨*

- មានការស៊ើបអង្កេតជាច្រើនទៅលើការប្រកួតប្រជែងជាអន្តរជាតិ ដែលបង្ហាញថាប្រទេសកម្ពុជានឹងតម្រូវឱ្យមានច្បាប់ស្តីពីការប្រកួតប្រជែងមួយដ៏មានប្រសិទ្ធភាព ដើម្បីធ្វើការសហការនិងសម្របសម្រួលជាមួយស្ថាប័នអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែងនៅក្នុងយុត្តាធិការផ្សេងៗទៀតដូចជា៖
    - សកម្មភាពដែលប្រព្រឹត្តនៅក្រៅប្រទេសកម្ពុជា ដែលអាចជះឥទ្ធិពលដល់ទីផ្សារនៅក្នុងប្រទេសកម្ពុជា។ ឧទាហរណ៍៖ ការរួមបញ្ចូលគ្នានៃធុរកិច្ចរវាងក្រុមហ៊ុនបរទេស និងការប្រព្រឹត្តបទល្មើសកាតែលជាអន្តរជាតិ
    - ជាក់ស្តែងក៏តម្រូវឱ្យប្រទេសកម្ពុជា ធ្វើការស៊ើបអង្កេតដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចនៃប្រទេសផ្សេងៗដែរ។
    - កិច្ចសហប្រតិបត្តិការរវាងស្ថាប័នជាតិ អាចជួយធ្វើការសម្រួលឬផ្តល់ជាវិធីសាស្ត្រសមស្របលើប្រតិបត្តិការអន្តរជាតិ។ ឧទាហរណ៍៖ Grab និង Uber

## ការផ្តោតទៅលើសេចក្តីណែនាំនៅក្នុងអាស៊ាន ឬ ថ្នាក់តំបន់

*ដើម្បីឱ្យអាស៊ានក្លាយជាតំបន់ប្រកួតប្រជែងជាមួយនឹងទីផ្សារដែលមានដំណើរការល្អ គឺមានការទាមទារឱ្យច្បាប់ស្តីពីការប្រកួតប្រជែងមានដំណើរការដើរទៅមុខនិងមានប្រសិទ្ធភាព។ គោលដៅសំខាន់នៃគោលនយោបាយនិងច្បាប់ស្តីពីការប្រកួតប្រជែង គឺដើម្បីផ្តល់នូវទីលានប្រកួតប្រជែងគ្នាមួយសម្រាប់ក្រុមហ៊ុនទាំងអស់ ដោយមិនគិតពីភាពជាម្ចាស់។ ច្បាប់ស្តីពីការប្រកួតប្រជែងដែលអាចយកមកធ្វើការអនុវត្តបាន គឺមានចែងនូវសកម្មភាពដែលរារាំងដល់ការប្រកួតប្រជែង ដើម្បីជាមធ្យោបាយដ៏សំខាន់មួយក្នុងការជួយសម្រួលដល់ការធ្វើសេរីភាវូបនីយកម្ម ការបង្រួបបង្រួមទីផ្សារ និងមូលដ្ឋានផលិតកម្ម ក៏ដូចជាគាំទ្រដល់ការបង្កើតតំបន់មួយដែលមានការប្រកួតប្រជែងនិងថ្លៃប្រឹតបន្ថែមទៀត។*

*ដកស្រង់ចេញផែនការផែនការលម្អិតសហគមន៍សេដ្ឋកិច្ចអាស៊ាន ២០២៥ មាត្រា ២៦*

- នៅពេលដែលទីផ្សារក្នុងតំបន់អាស៊ានមានការរីកចម្រើន ហើយមានឱកាសកាន់តែច្រើនឡើងសម្រាប់ពាណិជ្ជកម្ម និងការវិនិយោគទាំងក្នុងតំបន់និងពិភពលោកនោះ ប្រទេសកម្ពុជានឹងត្រូវធានាថា ការធ្វើពាណិជ្ជកម្មក្នុងស្រុកមានប្រសិទ្ធភាពនិងផលិតភាព តាមរយៈសេដ្ឋកិច្ចទីផ្សារក្នុងស្រុកដែលមានការប្រកួតប្រជែង ដូច្នេះពួកគេអាចប្រកួតប្រជែងនិងប្រកបអាជីវកម្មបានប្រកបដោយប្រសិទ្ធភាពទាំងនៅតាមបណ្តារដ្ឋសមាជិកអាស៊ាននិងជុំវិញពិភពលោកផងដែរ។
- ការអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែងរឹងមាំ នឹងការពារអ្នកចូលរួមទីផ្សារកម្ពុជា ពីសកម្មភាពដែលរារាំងដល់ការប្រកួតប្រជែងពីក្រុមហ៊ុនបរទេស ដែលកំពុងធ្វើអាជីវកម្មនៅក្នុង ឬចូលមកក្នុងប្រទេសកម្ពុជា ដែលអាចមានធនធានច្រើនជាងក្រុមហ៊ុនក្នុងស្រុក ហើយអាចមានលទ្ធភាពបំពានលើអំណាចទីផ្សារ។
- ផែនការសកម្មភាពប្រកួតប្រជែងអាស៊ាន (២០១៦-២០២៥) មានគោលដៅយុទ្ធសាស្ត្រចំនួន ០៥ ដែលរួមមាន៖

  ១. ច្បាប់ស្តីពីការប្រកួតប្រជែងប្រកបដោយប្រសិទ្ធភាព ត្រូវបង្កើតឡើងនៅក្នុងរដ្ឋសមាជិកអាស៊ានទាំងអស់

  ២. សមត្ថភាពរបស់ស្ថាប័នអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែងនៅក្នុងរដ្ឋសមាជិកអាស៊ានទាំងអស់ ត្រូវបានពង្រឹងដើម្បីអនុវត្តគោលនយោបាយនិងច្បាប់ស្តីពីការប្រកួតប្រជែងប្រកបដោយប្រសិទ្ធភាព

  ៣. ការរៀបចំកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ស្តីពីគោលនយោបាយនិងច្បាប់ស្តីពីការប្រកួតប្រជែងត្រូវបានអនុវត្ត

  ៤. ការជំរុញតំបន់អាស៊ានឱ្យក្លាយជាតំបន់មួយ ដែលមានការយល់ដឹងអំពីការប្រកួតប្រជែង

  ៥. ការឆ្ពោះទៅរកការរួបរួមគ្នាកាន់តែខ្លាំងនៃគោលនយោបាយនិងច្បាប់ស្តីពីការប្រកួតប្រជែងក្នុងអាស៊ាន។

- ការអនុម័តនិងការអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែងប្រកបដោយប្រសិទ្ធភាព អាចធ្វើឡើងដោយការប្រៀបធៀបទៅនឹងច្បាប់ស្តីពីការប្រកួតប្រជែងរបស់បណ្តារដ្ឋសមាជិកអាស៊ានផ្សេងទៀត ដែលនេះគឺជាការបោះជំហានដ៏សំខាន់មួយរបស់កម្ពុជាដើម្បីឆ្ពោះទៅរកការសម្រេចគោលដៅទាំងនេះ។
- ករណីប្រកួតប្រជែង គឺអាចទាមទារឱ្យមានកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលរវាងស្ថាប័នអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែងនៅក្នុងបណ្តារដ្ឋសមាជិកអាស៊ាន ក៏ដូចជាស្ថាប័ននៅក្នុងដែនសមត្ថកិច្ចផ្សេងៗទៀតដូចជា៖
    - ការសម្របសម្រួលរវាងស្ថាប័នអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែងក្នុងការប្រមូលភស្តុតាង
    - ការចែករំលែកនូវភស្តុតាងនិងវិធីសាស្ត្រក្នុងការវិភាគ ជាពិសេសលើករណីដែលមានសមាសធាតុជាអន្តរជាតិ
    - ការស្វែងរកនូវជំនាញការនិងមតិយោបល់។ ឧទាហរណ៍៖ នៅពេលដែលស្ថាប័នអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែងផ្សេងទៀតបានពិនិត្យមើលករណីឬវិស័យស្រដៀងគ្នា។

*ការរួបរួមគ្នាកាន់តែខ្លាំងឡើងនៃគោលនយោបាយនិងច្បាប់ស្តីពីការប្រកួតប្រជែងនៅក្នុងអាស៊ាន ត្រូវបានគេរំពឹងថានឹងបង្កើតបរិយាកាសតភ្ជាប់គោលនយោបាយសម្រាប់ ទំនិញ សេវាកម្ម និងទីក្រុងក្នុងការធ្វើដំណើរដោយសេរី និងគ្មានឧបសគ្គ។ ស្របពេលដែលក្រុមហ៊ុនអាចធ្វើប្រតិបត្តិការ និងបែងចែកនូវធនធានរបស់ពួកគេតាមរបៀបដែលមានប្រសិទ្ធភាពបំផុត។ វាក៏បានចូលរួមចំណែកក្នុងការលើកកម្ពស់តម្លាភាព និងការព្យាករណ៍ពីបរិយាកាសវិនិយោគផងដែរ។*

*ដកស្រង់ចេញពីផែនការសកម្មភាពប្រកួតប្រជែងអាស៊ាន (២០១៦-២០២៥) ទំព័រ០៨*

## III. ទំនាក់ទំនងនៃច្បាប់ស្តីពីការប្រកួតប្រជែងនៅក្នុងអាស៊ាន និងអន្តរជាតិ

**ចំណុចសំខាន់**

- ច្បាប់ស្តីពីការប្រកួតប្រជែង គឺមានច្រើនទម្រង់ បើទោះបីជានៅក្នុងតំបន់អាស៊ានតែមួយក៏ដោយ ប៉ុន្តែយើងឃើញថាបទប្បញ្ញត្តិមួយចំនួនមានលក្ខណៈស្រដៀងគ្នានៅក្នុងច្បាប់ស្តីពីការប្រកួតប្រជែងភាគច្រើន។
- នៅក្នុងច្បាប់ស្តីពីការប្រកួតប្រជែងដែលបានស្នើឡើងរបស់ប្រទេសកម្ពុជា គឺមានលក្ខណៈស្របទៅនឹងការអនុវត្តទាំងនៅក្នុងអាស៊ាននិងអន្តរជាតិ បើប្រៀបធៀបទៅនឹងក្របខ័ណ្ឌនៃច្បាប់នេះជាទូទៅ។
- ទាក់ទងទៅនឹងការហាមឃាត់សំខាន់ៗនៃច្បាប់ស្តីពីការប្រកួតប្រជែងដែលបានស្នើឡើងរបស់ប្រទេសកម្ពុជា ត្រូវបានអនុវត្តយ៉ាងទូលំទូលាយដែលស្របជាមួយការអនុវត្តអន្តរជាតិ។
- ការពិន័យនិងការដាក់ទណ្ឌកម្មនៅក្នុងច្បាប់ស្តីពីការប្រកួតប្រជែង អាចមានភាពខុសប្លែកគ្នារវាងយុត្តាធិការ ហើយក៏អាចមានការបញ្ចូលនូវ ការពិន័យព្រហ្មទណ្ឌ ការដាក់ពន្ធនាគារ ការពិន័យរដ្ឋបាល ការដោះស្រាយផ្សេងៗជាដើម។ ការពិន័យដែលមានចែងក្នុងមាត្រា៣៥ ៣៧ និង៣៨ គឺមានស្របតាមការអនុវត្តអន្តរជាតិភាគច្រើន។
- គួរឱ្យកត់សម្គាល់ផងដែរថា គោលនយោបាយនិងច្បាប់ស្តីពីការប្រកួតប្រជែង គឺមានការប្រែប្រួល ប៉ុន្តែវាគួរតែជាការវិវត្តន៍មួយដែលឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរទីផ្សារ និងភាពស្របច្បាប់ឱ្យកាន់តែមានប្រសិទ្ធភាព។ បច្ចុប្បន្ននេះ មិនមានច្បាប់ស្តីពីការប្រកួតប្រជែងមានភាពល្អឥតខ្ចោះនោះទេ ប៉ុន្តែមានតែការប្តេជ្ញាចិត្តក្នុងការពិនិត្យ ការវាយតម្លៃឡើងវិញនូវគោលនយោបាយនិងច្បាប់ស្តីពីការប្រកួតប្រជែង និងការធ្វើវិសោធនកម្មទេ ទើបធ្វើឱ្យច្បាប់នេះកាន់តែមានប្រសិទ្ធភាព។
- ដូចបានកត់សម្គាល់ខាងលើទាំងប្រទេសវៀតណាមនិងប្រទេសថៃនាពេលថ្មីៗនេះ មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ទៅលើច្បាប់ស្តីពីការប្រកួតប្រជែងរបស់ពួកគេ ចំណែកឯរដ្ឋសមាជិកអាស៊ានផ្សេងទៀតកំពុងធ្វើការត្រួតពិនិត្យជាប្រចាំ និងខ្លះទៀតបានធ្វើការផ្លាស់ប្តូរបន្តិចបន្តួចផងដែរ។

**មតិយោបល់**

- មិនមានច្បាប់ស្តីពីការប្រកួតប្រជែងណាដែលទទួលស្គាល់ជាលក្ខណៈអន្តរជាតិនោះទេ ដូច្នេះគោលនយោបាយនិងច្បាប់ស្តីពីការប្រកួតប្រជែង គឺត្រូវរៀបចំទៅតាមកត្តាសេដ្ឋកិច្ច និងច្បាប់របស់ប្រទេសនីមួយៗ។
- ទោះយ៉ាងនេះក្តី ជាទូទៅក៏នៅមានលក្ខណៈសណ្ឋានមួយចំនួន ដែលត្រូវបានបញ្ចូលទៅក្នុងច្បាប់ស្តីពីការប្រកួតប្រជែង។ គោលការណ៍ណែនាំក្នុងតំបន់អាស៊ាន បានរៀបរាប់នូវធាតុចំនួន ២១ ដែលអាចត្រូវបញ្ចូល។ ចំណែកអង្គការផ្សេងទៀតដូចជា UNCTAD និង OECD បានបង្កើតច្បាប់គំរូស្តីពីការប្រកួតប្រជែង ឬការណែនាំផ្សេងទៀតដែលដាក់ចេញនូវវិធីសាស្ត្រផ្សេងៗគ្នាចំពោះបញ្ហាច្បាប់ស្តីពីការប្រកួតប្រជែង។
- នៅក្នុងសម័យទំនើបនេះ ច្បាប់ស្តីពីការប្រកួតប្រជែងត្រូវបានរំពឹងថាមានបទប្បញ្ញត្តិទាក់ទងនឹង៖
    - វិសាលភាពនិងការអនុវត្តច្បាប់
    - អាជ្ញាធរមានសមត្ថកិច្ច
    - ការហាមឃាត់សំខាន់ៗដូចជា ការព្រមព្រៀងដែលរារាំងរឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង ការរំលោភបំពានដោយប្រើជំហរឧត្តមភាពលើទីផ្សារ និងការរួមបញ្ចូលគ្នានៃធុរកិច្ចដែលរារាំងដល់ការប្រកួតប្រជែង និងការធ្វើធុរកិច្ចមិនស្មោះត្រង់ផ្សេងៗទៀត
    - ដំណើរការស៊ើបអង្កេត
    - ដំណើរការចេញសេចក្តីសម្រេច
    - ការពិន័យ និង
    - សិទ្ធិឯកជន
- ដូចដែលបានភ្ជាប់ជាមួយឧបសម្ព័ន្ធទី១ គឺជាតារាងលម្អិតប្រៀបធៀបបទប្បញ្ញត្តិជាមូលដ្ឋាននៃច្បាប់ស្តីពីការប្រកួតប្រជែងអាស៊ាន ដែលដកស្រង់ចេញពីសៀវភៅណែនាំរបស់លេខាធិការដ្ឋានអាស៊ានស្តីពីគោលនយោបាយនិងច្បាប់ប្រកួតប្រជែងក្នុងអាស៊ានសម្រាប់ធុរកិច្ចឆ្នាំ២០១៧។ គួរបញ្ជាក់ផងដែរថា ព័ត៌មានដែលមាននៅក្នុងតារាងខាងក្រោម គឺផ្អែកលើសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែងនៅកម្ពុជាដែលមិនបានឆ្លុះបញ្ចាំងពេញលេញលើសេចក្តីព្រាងច្បាប់បច្ចុប្បន្នដែលបានស្នើឡើងបច្ចុប្បន្ននោះទេ។ (ឧទាហរណ៍៖ បច្ចុប្បន្នសេចក្តីព្រាងច្បាប់បានហាមឃាត់ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលរារាំងដល់ការប្រកួតប្រជែង ហើយវាត្រូវបានគេសន្និដ្ឋានថាអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ «ក.ប.ប.» ជាស្ថាប័នអនុវត្តទាំងច្បាប់ស្តីពីការប្រកួតប្រជែងនិងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់)។ ប៉ុន្តែទោះបីព័ត៌មាននេះមិនបានដាក់នូវទិន្នន័យថ្មី ហើយមិនបានឆ្លុះបញ្ចាំងយ៉ាងពេញលេញពីបទប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែងក៏ដោយ ក៏តារាងដែលបានដាក់ភ្ជាប់នេះក៏នៅតែជាភស្តុតាង ដោយហេតុថា សូម្បីតែសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែងដំបូងរបស់ប្រទេសកម្ពុជា ក៏បានយកទៅធ្វើការប្រៀបធៀបជាមួយបណ្តារដ្ឋសមាជិកអាស៊ានផ្សេងទៀតដែលបានដាក់អនុម័តច្បាប់នេះរួចហើយ។
- នៅក្នុងតារាងខាងក្រោម "សសរស្តម្ភទាំងបី" នៃការហាមឃាត់សំខាន់ៗនៃច្បាប់ស្តីពីការប្រកួតប្រជែង ត្រូវបានប្រៀបធៀបនៅក្នុងរដ្ឋសមាជិកអាស៊ាន (ផ្អែកលើច្បាប់ស្តីពីការប្រកួតប្រជែងរបស់ប្រទេសកម្ពុជាដែលបានស្នើឡើងនាពេលបច្ចុប្បន្ននេះ)

| **ប្រទេស** | **ការព្រមព្រៀង ដែលរារាំងរឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង** | **ការរំលោភបំពានដោយប្រើជំហរឧត្តមភាពលើទីផ្សារ** | **ការរួមបញ្ចូលគ្នានៃធុរកិច្ច ដែលរារាំងដល់ការប្រកួតប្រជែង** |
|---|---|---|---|
| **ប្រ៊ុយណេ** | X | X | X |

| | | | |
|---|---|---|---|
| **កម្ពុជា** | X | X | X |
| **ឥណ្ឌូនេស៊ី** | X | X | X |
| **ឡាវ** | X | X | X |
| **ម៉ាឡេស៊ី** | X | X | N/A (ស្ថិតនៅក្នុងការពិចារណា) |
| **មីយ៉ាន់ម៉ា** | X | X | X |
| **ហ្វីលីពីន** | X | X | X |
| **សិង្ហបុរី** | X | X | X |
| **ថៃ** | X | X | X |
| **វៀតណាម** | X | X | X |

**ការព្រមព្រៀងដែលរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង**

*៣.២.១. យោងតាមគោលការណ៍ណែនាំក្នុងតំបន់អាស៊ានស្តីពីគោលនយោបាយប្រកួតប្រជែង បណ្តារដ្ឋសមាជិកអាស៊ានគួរតែពិចារណាការហាមឃាត់កិច្ចព្រមព្រៀងខ្សែដេក និង ខ្សែឈរដែលរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងនៅក្នុងបណ្តារដ្ឋសមាជិក លុះត្រាតែមានករណីលើកលែង។*

- មានវិធីសាស្ត្រជាច្រើនដែលត្រូវបានអនុវត្តជាអន្តរជាតិ ដើម្បីគ្រប់គ្រងការព្រមព្រៀងដែលរារាំងដល់ការប្រកួតប្រជែង ដូចជា៖
    - ចំពោះយុត្តាធិការខ្លះ អនុវត្តលើតែការព្រមព្រៀងខ្សែដេកតែប៉ុណ្ណោះ (រវាងគូប្រកួតប្រជែង) ខណៈពេលដែលប្រទេសខ្លះទៀតបានអនុវត្តលើការព្រមព្រៀងខ្សែឈរផងដែរ (រវាងបុគ្គលស្ថិតនៅក្នុងកម្រិត ខុសគ្នានៃខ្សែច្រវាក់ផ្គត់ផ្គង់)
    - យុត្តាធិការខ្លះ មានការហាមឃាត់ទៅលើសកម្មភាពដូចបានកំណត់ជាបទល្មើសដោយស្វ័យប្រវត្តិ (Per Se) ខណៈពេលដែលប្រទេសខ្លះទៀតបានអនុវត្តនូវវិធានហេតុផល (Rule of Reason) ដោយត្រូវតែមានកម្មវត្ថុ ឬ ផលប៉ះពាល់ដល់ការប្រកួតប្រជែង
    - យុត្តាធិការខ្លះមានការអនុវត្តនូវទោសព្រហ្មទណ្ឌ (រាប់បញ្ចូលទាំងការដាប់ពន្ធនាគារ) ឬការដាក់ទណ្ឌកម្មផ្នែករដ្ឋបាល ឬទាំងពីរ (ឧទាហរណ៍ បច្ចុប្បន្ននេះប្រទេសវៀតណាមដាក់ទោសពិន័យផ្នែករដ្ឋបាលលើការព្រមព្រៀងដែលរារាំងដល់ការប្រកួតប្រជែង នៅក្រោមច្បាប់ស្តីពីការប្រកួតប្រជែង និងទោសព្រហ្មទណ្ឌក្រោមក្រមព្រហ្មទណ្ឌរបស់ខ្លួន)
    - យុត្តាធិការខ្លះ អនុញ្ញាតឱ្យមានការលើកលែង (ឧទាហរណ៍ សម្រាប់ប្រសិទ្ធភាពដល់សន្តិសុខជាតិ) និង
    - យុត្តាធិការខ្លះទៀតមាននីតិវិធីទាមទារឱ្យមានការត្រួតពិនិត្យជាមុនសិន។
- ការព្រមព្រៀងដែលរារាំងដល់ការប្រកួតប្រជែង មានចំនួន០៤ប្រភេទ ដែលជាទូទៅហៅថា "ចំណុចស្នូលនៃបទល្មើសកាតែល" (Hard-core Cartel) ដែលត្រូវបានគេចាត់ទុកជាទូទៅថាជាបទល្មើសដោយស្វ័យប្រវត្តិ ហើយត្រូវទទួលទោសព្រហ្មទណ្ឌ (ក៏ប៉ុន្តែមានយុត្តាធិការជាច្រើនរាប់បញ្ចូលទាំងសហគមន៍អឺរ៉ុបផងដែរនោះ គឺមិនមានការដាក់

ទោសព្រហ្មទណ្ឌទេ លើចំណុចស្នូលនៃបទល្មើសកាតែល-Hard-core Cartel)។ បន្ថែមពីនេះទៀតការសម្រេចថាបទល្មើសទាំងនោះមានផលប៉ះពាល់ គឺនៅពេលមាន៖

- ការព្រមព្រៀងដើម្បីកំណត់ថ្លៃ
- ការព្រមព្រៀងដើម្បីកំណត់បរិមាណ ឬ ប្រភេទនៃទំនិញ ឬ សេវា
- ការព្រមព្រៀងដើម្បីបែងចែកតំបន់ភូមិសាស្ត្រ ឬ អតិថិជន
- ការឃុបឃិតគ្នាក្នុងការដេញថ្លៃ

- មាត្រា៧ នៃច្បាប់ស្តីពីការប្រកួតប្រជែងបានហាមឃាត់នូវចំណុចស្នូលនៃបទល្មើសកាតែលទាំងនេះ ដែលមានការជះឥទ្ធិពលណាមួយមកលើការប្រកួតប្រជែង (ទោះបីជាការហាមឃាត់ការឃុបឃិតគ្នាក្នុងការដេញថ្លៃនោះ ត្រូវបានកំណត់តែលើលទ្ធកម្មឯកជនក៏ដោយ)។ មួយវិញទៀត មាត្រានេះក៏បានហាមឃាត់នូវបទល្មើសកាតែលផ្សេងៗដែលឈរលើមូលដ្ឋាននៃបទល្មើសកាតែល ដែលមានកម្មវត្ថុ ឬ ផលប៉ះពាល់ដល់ការប្រកួតប្រជែងផងដែរ។
- មាត្រា៨ នៃច្បាប់ស្តីពីការប្រកួតប្រជែងបានហាមឃាត់នូវការព្រមព្រៀងខ្សែឈរតាមរបៀបដូចខាងក្រោម៖
  - ការកំណត់ថ្លៃក្នុងការលក់រាយគឺត្រូវបានហាមឃាត់
  - ការព្រមព្រៀងខ្សែឈរផ្សេងទៀតដែលមាន ឬ អាចមានកម្មវត្ថុ ឬ អានុភាពរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង (ដូចមានចែងនៅក្នុងមាត្រា)។
- ទោះបីជាមានការទាមទារនូវគោលការណ៍ណែនាំអំពីរបៀបអនុវត្តពាក់ព័ន្ធនឹងបទប្បញ្ញត្តិទាំងនេះ ប៉ុន្តែនៅក្នុងដំណាក់កាលនេះ ជាទូទៅគឺបទប្បញ្ញត្តិដែលមានចែងបានស្ថិតនៅក្នុងវិសាលភាពនៃការអនុវត្តជាអន្តរជាតិ លើការគ្រប់គ្រងការព្រមព្រៀងដែលរារាំងដល់ការប្រកួតប្រជែងផងដែរ។

<u>**ការរំលោភបំពានដោយប្រើជំហរឧត្តមភាពលើទីផ្សារ**</u>

*៣.៣.១ បណ្តារដ្ឋសមាជិកអាស៊ានគួរតែពិចារណាហាមឃាត់លើការរំលោភបំពានដោយប្រើជំហរឧត្តមភាពលើទីផ្សារ៖*

*៣.៣.១.១ "ជំហរឧត្តមភាព" សំដៅទៅលើអំណាចទីផ្សារដែលការធ្វើសកម្មភាពការជាលក្ខណៈបុគ្គល ឬរួមគ្នាជាមួយបុគ្គលផ្សេងទៀត ស្ថិតនៅក្នុងជំហរមួយដែលអាចធ្វើឱ្យប៉ះពាល់ដល់កម្រិតប្រកួតប្រជែងនៅក្នុងទីផ្សារ។ ឧទាហរណ៍ សកម្មភាពទាំងនោះអាចជានាបាននូវថ្លៃខ្ពស់ជាងកម្រិតប្រកួតប្រជែង ឬ រឹតត្បិតបរិមាណ ឬគុណភាពទាបជាងកម្រិតប្រកួតប្រជែង។ បណ្តារដ្ឋសមាជិកអាស៊ាន គួរតែពិចារណាថាតើច្បាប់ស្តីពីការប្រកួតប្រជែងគួរមានការកម្រិតកំណត់ នៃចំណែកទីផ្សារដែរទេ។*

*៣.៣.១.២ "ការរំលោភបំពាន" ដោយប្រើជំហរឧត្តមភាពកើតឡើង នៅពេលដែលក្រុមហ៊ុនមួយមានជំហរឧត្តមភាព លក្ខណៈបុគ្គល ឬរួមគ្នាជាមួយសកម្មភាពផ្សេងទៀតធ្វើការបង្ខូចដល់ទីផ្សារពាក់ព័ន្ធដោយប្រើជំហរឧត្តមភាព ឬ ធ្វើឱ្យគូប្រកួតប្រជែងដើរចេញពីទីផ្សារ និងធ្វើឱ្យមានផលប៉ះពាល់ដល់ដំណើរការប្រកួតប្រជែង។ នេះជាការប្រុងប្រយ័ត្នមួយក្នុងការពិចារណាលើផលប៉ះពាល់ជាក់ស្តែង ឬនឹងអាចកើតមានឡើងពីសកម្មភាពរបស់ពួកគេមកលើការប្រកួតប្រជែង ជាងការកំណត់ថាសកម្មភាពរបស់ក្រុមហ៊ុនមួយមានជំហរឧត្តមភាពទាំងនោះត្រូវបានរំលោភបំពានដោយស្វ័យប្រវត្តិ។*

***ដកស្រង់ចេញពី គោលការណ៍ណែនាំក្នុងតំបន់អាស៊ានស្តីពីគោលនយោបាយប្រកួតប្រជែង***

- ការរំលោភបំពានដោយប្រើជំហរឧត្តមភាពលើទីផ្សារ ជាផ្នែកមួយដែលមានភាពស្មុគស្មាញ ក្នុងចំណោមជាតុផ្សេងៗនៃច្បាប់ស្តីពីការប្រកួតប្រជែង និងត្រូវអនុវត្តតាមវិធីសាស្ត្រផ្សេងៗគ្នាទាក់ទិនទៅនឹងការកំណត់អំណាចទីផ្សារ ឬ ជំហរឧត្តមភាព និងការកំណត់នូវសកម្មភាព ដែលពេលខ្លះសកម្មភាពទាំងនោះអាចនឹងមិនមានបញ្ហា ដែលគួរកំណត់ថាជាការរំលោភបំពាននោះទេ។

- ចំណុចសំខាន់ គឺត្រូវធានាថាការមានជំហរឧត្តមភាព ឬអំណាចទីផ្សារគឺមិនគួរមានការហាមឃាត់ ប៉ុន្តែនៅពេលអំណាចរបស់ខ្លួនត្រូវបានប្រើប្រាស់ក្នុងគោលបំណងរារាំងដល់ការប្រកួតប្រជែង ឬមានផលប៉ះពាល់កើតឡើងនោះ ទើបវាជាការបំពាន។

- មាត្រា៩ នៃច្បាប់ស្តីពីការប្រកួតប្រជែងបានហាមឃាត់នូវសកម្មភាពជាក់លាក់ និងការប្រព្រឹត្តមួយចំនួនទៀត ដោយបុគ្គលមានអំណាចទីផ្សារ ប្រសិនបើការប្រព្រឹត្តនេះមានកម្មវត្ថុ ឬ អានុភាពរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង។
- មាត្រា១០ នៃច្បាប់ស្តីពីការប្រកួតប្រជែងបានផ្តល់នូវការលើកលែងមានកំណត់ ប្រសិនបើបុគ្គលនោះអាចបញ្ជាក់នូវមូលហេតុសមស្រប។
- មាត្រា៣(៦) បានកំណត់នូវនិយមន័យជំហរឧត្តមភាពលើទីផ្សារ ដោយសំដៅដល់ស្ថានភាពដែលបុគ្គលណាមួយមានអំណាចទីផ្សារដែលគួរឱ្យកត់សម្គាល់ដោយគ្មានការរារាំងដល់គូប្រកួតប្រជែងផ្សេងទៀត។
- ស្របពេលដែលមានការបញ្ជាក់មួយចំនួនដែលត្រូវផ្តល់ដោយបទប្បញ្ញត្តិ ឬគោលការណ៍ណែនាំ ដូចជាលើការកំណត់នូវអំណាចទីផ្សារ វិធីសាស្ត្រត្រូវបានយកទៅអនុវត្តនៅក្នុងច្បាប់ស្តីពីការប្រកួតប្រជែង ក្នុងការដោះស្រាយការរំលោភបំពានដោយប្រើជំហរឧត្តមភាពលើទីផ្សារ គឺស្ថិតក្នុងវិសាលភាពនៃការអនុវត្តជាអន្តរជាតិ។

<u>**ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលរារាំងដល់ការប្រកួតប្រជែង**</u>

*៣.៤.១ ជាគោលការណ៍ការរួមបញ្ចូលគ្នានៃធុរកិច្ច គឺជាប្រតិបត្តិការពាណិជ្ជកម្មស្របច្បាប់រវាងប្រតិបត្តិករសេដ្ឋកិច្ច។ ទោះជាយ៉ាងណាបណ្តារដ្ឋសមាជិកអាស៊ាន អាចពិចារណាក្នុងការហាមឃាត់លើការរួមបញ្ចូលគ្នានៃធុរកិច្ចទាំងឡាយ ណាដែលមាន ឬ អាចមានកម្មវត្ថុឬអានុភាពរាំងរឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងគួរឱ្យកត់សម្គាល់នៅក្នុងទីផ្សារ លើកលែងតែមានករណីលើកលែង។*

*ដកស្រង់ចេញពី គោលការណ៍ណែនាំក្នុងតំបន់អាស៊ានស្តីពីគោលនយោបាយប្រកួតប្រជែង*

- មាត្រា១១ នៃច្បាប់ស្តីពីការប្រកួតប្រជែងបានហាមឃាត់ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលរារាំងដល់ការប្រកួតប្រជែងតាមការអនុវត្តអន្តរជាតិដែលសកម្មភាពនេះត្រូវបានហាមឃាត់ និងកំណត់។
- ប៉ុន្តែសេចក្តីលម្អិតលើការគ្រប់គ្រងក្នុងការរួមបញ្ចូលគ្នានៃធុរកិច្ច (ឧទាហរណ៍៖ កម្រិតកំណត់ក្នុងការហាមឃាត់ នីតិវិធីនៃការជូនដំណឹងនិងការដោះស្រាយផ្សេងៗទៀត) នឹងមានចែងនៅក្នុងអនុក្រឹត្យនិងការកំណត់ ដោយគណៈកម្មាធិការប្រកួតប្រជែង។ ដូច្នេះមិនទាន់មានការប្រៀបធៀបណាមួយជាក់លាក់ទៅលើការអនុវត្តជាអន្តរជាតិនោះទេ។

<u>**បទប្បញ្ញត្តិផ្សេងទៀត**</u>

- ច្បាប់ស្តីពីការប្រកួតប្រជែងដែលត្រូវបានស្នើឡើងនេះ ជាទូទៅគឺមានភាពស្របតាមរដ្ឋសមាជិកអាស៊ាន និងការអនុវត្តជាអន្តរជាតិ ដែលនៅក្នុងទម្រង់បែបបទនិងវិធីសាស្ត្រស្របទៅតាមទស្សនៈវិស័យច្បាប់ និងសេដ្ឋកិច្ចនៅកម្ពុជា។
    - ពិសេសជាងនេះទៅទៀត គឺវាផ្តល់នូវជាតុមូលដ្ឋានទូទៅដូចដែលបានរៀបរាប់ខាងលើ។
    - គួរបញ្ជាក់ផងដែរថា ច្បាប់ស្តីពីការប្រកួតប្រជែងដែលត្រូវបានស្នើឡើងនេះ មិនបានផ្តល់សិទ្ធិក្នុងការធ្វើសកម្មភាពបុគ្គលឯកឯងបានទេ។ អ្វីគួរឱ្យកត់សម្គាល់នោះ គឺការផ្តល់នូវសំណងដល់ជនរងគ្រោះដែលបានកំណត់អត្តសញ្ញាណ ត្រូវបានធ្វើការពិចារណា។
- មួយវិញទៀត ការរំពឹងថាការត្រួតពិនិត្យសារឡើងវិញនៃច្បាប់ស្តីពីការប្រកួតប្រជែង គឺជាផ្នែកមួយនៃការអនុវត្តគោលនយោបាយប្រកួតប្រជែង ដើម្បីធានាថាវានៅតែមានប្រសិទ្ធភាព ក្នុងការការពារនិងលើកកម្ពស់សេដ្ឋកិច្ចទីផ្សារ របស់ប្រទេសកម្ពុជា។

  <u>**ឧទាហរណ៍៖**</u>

    - ប្រទេសវៀតណាមនិងប្រទេសថៃនាពេលថ្មីៗនេះ បានធ្វើវិសោធនកម្មទៅលើច្បាប់ស្តីពីការប្រកួតប្រជែងរបស់ពួកគេ។ ចំណែកឯប្រទេសម៉ាឡេស៊ី កំពុងពិចារណាក្នុងការបញ្ចូលនូវ បទប្បបញ្ញត្តិស្តីពីការរួមបញ្ចូលគ្នានៃធុរ

កិច្ចទៅក្នុងច្បាប់ ស្របពេលដែលប្រទេសឥណ្ឌូណេស៊ីបានធ្វើឬកំពុងពិចារណាក្នុងការធ្វើវិសោធនកម្មលើការរួមបញ្ចូលគ្នានៃធុរកិច្ច និងការអនុវត្តច្បាប់របស់ខ្លួនផងដែរ។ បើក្រឡេកមើលប្រទេស ប្រទេសហ្វីលីពីនវិញក៏បានពិនិត្យឡើងវិញនូវកម្រិតកំណត់នៃការរួមបញ្ចូលគ្នានៃធុរកិច្ច និងកំពុងពិចារណាក្នុងការធ្វើវិសោធនកម្មលើអំណាចរបស់បញ្ញត្តិករ។ល។

## IV. បញ្ហាប្រឈមសម្រាប់គោលនយោបាយប្រកួតប្រជែងនៅក្នុងអាស៊ាន

- បញ្ហាប្រឈមជាច្រើន ត្រូវបានកំណត់ជាទូទៅសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាព នៃគោលនយោបាយនិងច្បាប់ស្តីពីការប្រកួតប្រជែងជាពិសេសនៅក្នុងអាស៊ាន រួមមាន៖
    - កង្វះខាតនូវវប្បធម៌ប្រកួតប្រជែង ប្រព័ន្ធតុលាការ កង្វះខាតនូវទិន្នន័យសេដ្ឋកិច្ចនិងធុរកិច្ច បរិយាកាសនៃបទប្បញ្ញត្តិមិនគ្រប់គ្រាន់ អាទិភាពនៃគោលនយោបាយប្រកួតប្រជែង កង្វះខាតនូវធនធាន កង្វះខាតជំនាញប្រកួតប្រជែង ការបង្កើតនូវការយកចិត្តទុកដាក់ពីម្ចាស់អាជីវកម្ម។ល។
- ជាក់ស្តែង មិនទាន់មានដំណោះស្រាយដែលងាយឬឆាប់រហ័សនៅឡើយទេ ប៉ុន្តែមានយុទ្ធសាស្រ្តជាច្រើនដើម្បីជម្នះឧបសគ្គទាំងនេះ។ បញ្ហាសំខាន់ គឺការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់គោលនយោបាយប្រកួតប្រជែង (សារៈសំខាន់នៃបញ្ហានេះ ត្រូវបានពិភាក្សាខាងលើ)។ យុទ្ធសាស្រ្តទូទៅដើម្បីដោះស្រាយបញ្ហាប្រឈមរួមមាន៖
    - កិច្ចគាំទ្រក្នុងការលើកកម្ពស់វប្បធម៌ប្រកួតប្រជែង និងការអប់រំដល់ភាគីពាក់ព័ន្ធ ទាំងវិស័យឯកជននិងសាធារណៈ អំពីសិទ្ធិនិងការទទួលខុសត្រូវរបស់ពួកគេ។
    - កិច្ចគាំទ្ររបស់រដ្ឋាភិបាល សម្រាប់ការលើកកម្ពស់គោលនយោបាយនិងច្បាប់ស្តីពីការប្រកួតប្រជែងទៅក្នុងសេដ្ឋកិច្ចទាំងមូល ដែលនេះ គឺលើសពីការគាំទ្រផ្នែកហិរញ្ញវត្ថុទៅទៀត ដើម្បីរួមបញ្ចូលបញ្ហាដូចជា៖
        - ការធានានូវគោលនយោបាយនិងច្បាប់ស្តីពីការប្រកួតប្រជែង គឺនឹងត្រូវបានអនុវត្តដោយមិនមានភាពលម្អៀង ដើម្បីបង្ហាញពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងដំណើរការសេដ្ឋកិច្ចទីផ្សារឱ្យបានត្រឹមត្រូវដល់អ្នកចូលរួម និងអ្នកពាក់ព័ន្ធទាំងនៅក្នុងស្រុកនិងអន្តរជាតិ ដែគូពាណិជ្ជកម្មនិងវិនិយោគិន។
        - ការធានានូវច្បាប់និងបទប្បញ្ញត្តិផ្សេងទៀត ត្រូវបានអនុម័ត កែប្រែ និងអនុវត្តស្របតាមគោលនយោបាយនិងច្បាប់ស្តីពីការប្រកួតប្រជែង រួមទាំងការសម្របសម្រួលចាំបាច់ជាមួយបញ្ញត្តិករតាមវិស័យផ្សេងៗទៀត។
    - ការបណ្តុះបណ្តាលនិងការអភិវឌ្ឍន៍ (ដូចជាការពង្រឹងសមត្ថភាពជាដើម) នៅក្នុងគោលនយោបាយនិងច្បាប់ស្តីពីការប្រកួតប្រជែង នៅក្នុងកម្រិតផ្សេងៗគ្នា ដែលរួមមាន ស្ថាប័នអនុវត្តការប្រកួតប្រជែង និយ័តករតាមវិស័យផ្សេងៗ ស្ថាប័នតុលាការ អង្គនីតិប្បញ្ញត្តិ និងស្ថាប័នពាក់ព័ន្ធដទៃទៀត។
    - ការដាក់ចេញនូវការអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែងឱ្យបានឆាប់រហ័ស ដើម្បីធានាឱ្យមានរយៈពេលសមស្របដល់ស្ថាប័ន/និយ័តករអនុវត្តច្បាប់អាចផ្តោតលើការជំរុញដល់ការគាំទ្រច្បាប់និងការអប់រំ បន្ទាប់មកគឺជាជម្រើសក្នុងការអនុវត្តច្បាប់ ដែលបង្កលក្ខណៈឱ្យបញ្ញត្តិករអាចអភិវឌ្ឍសមត្ថភាពនិងបទពិសោធន៍ ហើយសម្រាប់អ្នកចូលរួមក្នុងទីផ្សារ អាចធ្វើការផ្លាស់ប្តូរអាកប្បកិរិយារបស់ពួកគេឱ្យស្របតាមច្បាប់ស្តីពីការប្រកួតប្រជែង។
        - ឧទាហរណ៍៖ នៅក្នុងយុត្តាធិការខ្លះ បន្ទាប់ពីរយៈពេលនៃផ្តោតលើការជំរុញដល់ការគាំទ្រច្បាប់មក គឺការហាមឃាត់នូវបទល្មើសកាតែលនឹងត្រូវបានអនុវត្តមុនគេ ព្រោះថាជាទូទៅបទល្មើសនេះមិនតម្រូវឱ្យមានការវិភាគសេដ្ឋកិច្ចដែលមានលក្ខណៈស្មុគស្មាញពេកនោះទេ។ បន្ទាប់មកនៅក្នុងរយៈពេលសមស្របណាមួយ នៅពេលដែលសមត្ថភាពរបស់ស្ថាប័នអនុវត្តច្បាប់ត្រូវបានអភិវឌ្ឍ បទល្មើសលើការរំលោភបំពានដោយប្រើជំហរឧត្តមភាពលើទីផ្សារនិងការរួមបញ្ចូលគ្នានៃធុរកិច្ច ត្រូវយកមកអនុវត្តបន្ទាប់។

- ជំនួយបច្ចេកទេសពីអាស៊ាននិងអន្តរជាតិ អាចដម្នះនូវបញ្ហាប្រឈមមួយចំនួនបានយ៉ាងឆាប់រហ័ស តាមរយៈការបង្កើនប្រសិទ្ធភាពនិងការបន្ថយចំណាយក្នុងចែករំលែកចំណេះដឹង វិធីសាស្ត្រនៃការអនុវត្តបទពិសោធន៍ ជំនាញ និងធនធានផ្សេងៗ ក៏ដូចជាកិច្ចសហប្រតិបត្តិការរវាងបញ្ញត្តិករ ដើម្បីជួយក្នុងការស៊ើបអង្កេតដែលកំពុងដំណើរការ និងបញ្ហានានាលើការអនុវត្ត។

*បញ្ហានៃការប្រកួតប្រជែងកាន់តែមានច្រើន ពាក់ព័ន្ធដល់បទល្មើសឆ្លងព្រំដែន។ ក្រុមហ៊ុននិងខ្សែសង្វាក់ផ្គត់ផ្គង់មានលក្ខណៈជាអន្តរជាតិ ខណៈពេលដែលច្បាប់ស្តីពីការប្រកួតប្រជែងនិងស្ថាប័នអនុវត្តច្បាប់ស្ថិតនៅក្នុងកម្រិតជាតិ។ បណ្តាប្រទេសនីមួយៗមានភាពលំបាក ក្នុងការដោះស្រាយនូវសកម្មភាពពារាំងដល់ការប្រកួតប្រជែងនៅកម្រិតអន្តរជាតិ ដែលទាមទារឱ្យមានកិច្ចសហការក្នុងតំបន់ និងពិភពលោកដើម្បីកំណត់និងអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែង។*

*ដកស្រង់ចេញពី អង្គការ UNCTAD "ហេតុអ្វីបានជាការប្រកួតប្រជែង និងកិច្ចការពារអ្នកប្រើប្រាស់សំខាន់"*

## V. សេចក្តីសន្និដ្ឋាន

- ច្បាប់ស្តីពីការប្រកួតប្រជែង គឺជាឧបករណ៍ចាំបាច់ ដើម្បីការពារ លើកកម្ពស់ និងពង្រីកសេដ្ឋកិច្ចទីផ្សារ។
- គោលនយោបាយនិងច្បាប់ស្តីពីការប្រកួតប្រជែងប្រកបដោយប្រសិទ្ធភាពជាទូទៅ ត្រូវបានផ្សារភ្ជាប់ទៅនឹងតម្លៃទាប ការកើនឡើងនៃប្រសិទ្ធភាព ការច្នៃប្រឌិតបន្ថែម ការកើនឡើងផលិតផលក្នុងស្រុក ការវិនិយោគផ្ទាល់ពីបរទេស និងការកាត់បន្ថយភាពក្រីក្រ។
- ប្រទេសកម្ពុជា ស្ថិតក្រោមការប្តេជ្ញាចិត្តនៅក្នុងឆាកអន្តរជាតិមួយចំនួនក្នុងការអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែង និងមានបទប្បញ្ញត្តិជាច្រើនទៀត។
- វត្តមានរបស់ប្រទេសកម្ពុជានៅក្នុងសេដ្ឋកិច្ចពិភពលោកទាំងផ្នែកពាណិជ្ជកម្មនិងការវិនិយោគ នឹងទទួលបាននូវអត្ថប្រយោជន៍ជាច្រើនពីការអនុវត្តគោលនយោបាយនិងច្បាប់ស្តីពីការប្រកួតប្រជែង។
- បច្ចុប្បន្ននេះ មិនទាន់មានទម្រង់រួមណាមួយនៃច្បាប់ស្តីពីការប្រកួតប្រជែងនោះទេ ប៉ុន្តែសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែងដែលត្រូវបានស្នើឡើងនេះ ជាទូទៅ គឺស្របតាមការអនុវត្ត ក្នុងតំបន់និងអន្តរជាតិ។
- ដើម្បីអនុវត្តគោលនយោបាយនិងច្បាប់ស្តីពីការប្រកួតប្រជែងប្រកបដោយប្រសិទ្ធភាព រាជរដ្ឋាភិបាលកម្ពុជា ត្រូវតែធានាថាការអនុវត្តនេះត្រូវបានគាំទ្រយ៉ាងត្រឹមត្រូវ រួមមានទាំងការវិនិយោគលើផ្នែកធនធានមនុស្ស ផ្នែកហិរញ្ញវត្ថុ និងផ្នែកនយោបាយ។